# មូលហេតុបង្ក (Criminal Causation)

១.ក្នុងរឿងព្រហ្មទណ្ឌទង្វើឬសកម្មភាពដែលជាធាតុផ្សំសម្ភារៈhttp://www.measboralaws.com/detail/1050 នាំឲ្យមានបច្ច័យនៃទង្វើនោះ។ ឧទាហរណ៍ ការបាញ់បណ្ដាលឲ្យបុគ្គលម្នាក់ស្លាប់។ នេះជា Causation។ ករណីនេះ មិនស្មុគ្រស្មាញទេ។ ក៏ប៉ុន្តែករណីខ្លះ មានភាពស្មុគ្រស្មាញ មានអ្នកចូលរួមក្នុងអំពើមួយឬច្រើន ដែលជាចំណែកបង្ក ឲ្យមានផលវិបាកជាក់លាក់ណាមួយ។ និយាយជាពិសេស ករណីមនុស្សឃាតដោយអចេតនា (Involuntary Manslaughter) ដែលមូលហេតុបណ្ដាលឲ្យស្លាប់ មានភាពមិនច្បាស់លាស់។ គ្រោះថ្នាក់ចរាចរមួយបានកើតឡើង ធ្វើឲ្យបុរសម្នាក់របួសហូរឈាម សន្លប់ស្ដូកស្ដឹង។ ឡានសង្គ្រោះបន្ទាន់បានមកដល់ តែយឺតយ៉ាវ ដោយសារស្ទះចរាចរ ជនរងគ្រោះបានស្លាប់ ២០ នាទីក្រោយពេលទៅដល់មន្ទីរពេទ្យ និងទទួលការព្យាបាល។ តើការស្លាប់បណ្ដាលមកពីរបួសពីដំបូង ឬបណ្ដាលមកពីការធ្វេសប្រហែសក្នុងការព្យាបាល?

២. មូលហេតុបង្ក មានពីរប្រភេទគឺតាមផ្លូវច្បាប់ (legal causation)និង តាមអង្គហេតុ (factual causation)។ ប្រភេទទី ១ គឺ ដើមហេតុបង្កដោយជនល្មើសដំបូង នៅតែមានដំណើរការ (operative) ទោះបីជា ការចូលរួមរបស់ជនល្មើស មិនមានអ្វីជាដុំកំភួន។ ផ្សេងពីនេះ គឺស្ថិតចូលក្នុងប្រភេទទី២។

៣. មូលហេតុបង្ក អាចចម្បង (primary) មានស្ថានភាពដូចគ្នា (equivalent condition) គ្រប់គ្រាន់ (adequate) ផ្ទាល់ (direct) មិនផ្ទាល់ (indirect) ឬកៀកកិត (proximate)។ ការណ៍អុចឈើគូស ជាមូលហេតុកៀកកិតនឹងការឆេះ។ បន្ថែមពីលើនេះ មានព្រឹត្តិការណ៍ ឬអង្គហេតុអន្តរាគមន៍ ដែលអាចនាំ ឲ្យផ្ដាច់ចំណងហេតុ (cause) និង ផលវិបាក (effect)។ ការស្ទះចរាចរណ៍ ក្នុងឧទាហរណ៍ ខាងលើ អាចជាអង្គហេតុនេះ (intervening event)។

៤. យុត្តាធិការក្នុងស្រុក ប្រកាន់យកនូវស្ដង់ដាផ្សេងៗគ្នា។ តុលាការខ្លះ ប្រកាន់យក មូលហេតុគ្រប់គ្រាន់និងផ្ទាល់ (adequate and direct cause) ឬជួនកាល ចម្រុះគ្នាទៅតាមអង្គហេតុនីមួយៗ។ យុត្តិសាស្ត្រនៃប្រទេសកំមុនទ្ស នឹងទទួលយកអង្គហេតុ ដែលនាំឲ្យកាត់ផ្ដាច់ចំណងហេតុ និង ផល (breach of causation chain) លុះត្រាជនល្មើសអាចប្រមើលឃើញ (foreseeable) ហើយមូលហេតុដំបូង លែងមានដំណើរការ (no longer in operative)។ ក្នុងករណីបង្ករបួសស្នាមលើជនរងគ្រោះ ជនរងគ្រោះរត់គេច រួចទៅបុកឡាន នាំឲ្យស្លាប់។ ជនល្មើស មិនបានប្រមើលដឹងថានឹងមានហេតុការណ៍នេះទេ ហើយរបួសនោះ មិនសមនឹងស្លាប់ ប្រសិនបើឡានមិនបានបុក។ អង្គហេតុផ្ដាច់ចំណង នឹងនាំឲ្យជនល្មើសមិនទទួលខុសត្រូវពីបទមនុស្សឃាតទេ។ ក៏ប៉ុន្តែ ជនល្មើសនៅទទួលខុសត្រូវពីបទ ដូចជា ហិង្សា ឬបង្ករបួសស្នាមដោយចេតនា។ ផ្ទុយទៅវិញ ប្រសិនរបួសបង្កមានសភាពធ្ងន់ធ្ងរ ដែលនឹងនាំឲ្យស្លាប់តាមធម្មជាតិ (natural cause of dying) ជនល្មើសនៅតែទទួលខុសត្រូវពីបទមនុស្សឃាតចេតនា ឬប៉ុនប៉ងមនុស្សឃាត។

៩. យុត្តិសាស្ត្រតុលាការអាមេរិក បានប្រើស្តង់ដាមួយ គឺ Thin Skull Test/Eggshell rule។ នេះកើតមានក្នុងករណី មានរបួសស្រាល តែបណ្តាលឲ្យជនរងគ្រោះស្លាប់បាន ដោយសារ ស្ថានភាពទន់ខ្សោយមិនរំពឹងទុកនៃជនរងគ្រោះ។ ក្នុងយុត្តិសាស្ត្រនេះ តុលាការពិនិត្យសំខាន់លើចេតនានៃជនល្មើស ហើយជនល្មើសមិនអាចយកស្ថានភាពនៃជនរងគ្រោះ ជាការដោះសារទេ។ យុត្តាធិការប្រទេសខ្លះ ប្រកាន់យក But For Test ដើម្បីសម្រេចថាមូលហេតុណាមួយ ជាដើមចមនាំឲ្យមានផលវិបាកនៃទង្វើនោះ។ ក្នុងន័យថា បើគ្មានសកម្មភាព X ទេ ក៏នឹងគ្មានផលវិបាក Z ដែរ។ រូបមន្តនេះ ត្រូវបានយកមកប្រើ ក្នុង Factual Causation និងក្នុងករណី មានមនុស្ស និងសកម្មភាពជាច្រើន ដែលនាំឲ្យមានការស្លាប់របស់ជនរងគ្រោះ។ ប្រសិនបើ រកមិនឃើញ មូលហេតុណាមួយជាក់លាក់ទេ ជនពាក់ព័ន្ធទាំងនេះ នឹងទទួលខុសត្រូវរួមគ្នា។ គេគួរកត់សំគាល់ថា សម្រាប់បទល្មើស ដែលទាមទារនូវ Causation ប្រសិនបើ រដ្ឋអាជ្ញា មិនបានបង្ហាញឲ្យឃើញនូវចំណងនៃអំពើ និងផលទេ ជនល្មើសនឹងមិនទទួលខុសត្រូវ។

**កំណត់សំគាល់**៖ បទល្មើសចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៩ ខ្លះ មិនចង្អុលពីមូលហេតុបង្កទេ។ បទល្មើសខ្លះបង្ហាញ...ដូចជា ទង្វើរបួស ដោយការធ្វេសប្រហែស...ដែល**បង្កឲ្យ**មានអសមត្ថភាពធ្វើការងារ..។ មាត្រា ៤៩៥ នៃក្រមដដែល ស្តីពី បទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ ត្រូវបានដកស្រង់ខ្លឹមសារទាំងស្រុង ដើម្បីបញ្ជាក់៖ *អំពើញុះញង់ដោយផ្ទាល់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬប្រព្រឹត្តអំពើបង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម តាមមធ្យោបាយណាមួយក្នុងចំណោមមធ្យោបាយ ដែលមានចែងនៅក្នុងមាត្រា ៤៩៤ (លក្ខខណ្ឌអត្ថិភាពនៃការញុះញង់) ...ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែទៅ ២ (ពីរ) ឆ្នាំ និងពិន័យ...*។

មានសាលក្រមតុលាការកំពូលមួយ ពាក់ព័ន្ធនឹងបទធ្វេសប្រហែសរបស់គ្រូពេទ្យ(medical malpractice)។ តុលាការកំពូលបានប្រើពាក្យ ការស្លាប់តាមដំណើរធម្មតា ដើម្បីកំណត់ថា តើការស្លាប់របស់កុមារ ដោយសារ ការធ្វេសប្រហែសរបស់គ្រូពេទ្យ ឬ មកពីស្ថានភាពសុខភាពកុមារធ្ងន់ធ្ងរ អាចស្លាប់បាន ទោះ បីជាគ្មានការធ្វេសប្រហែសក្តី។ *១. យល់ឃើញថា ការណ៍ដែលសាលាឧទ្ធរណ៍ ក៏ដូចអយ្យការអមតុលាការខេត្តកំពង់ចាមដែរ ដែលតម្កល់រឿងមរណៈភាពនៃកុមារ ទាំងពីរនាក់នេះ ពុំចាត់ការនោះ គឺជាការពុំត្រឹមត្រូវទេ ពីព្រោះថាពុំមានភ័ស្តុតាងណាមួយបញ្ជាក់ថាមរណៈភាពនៃកុមារទាំងពីរជាមរណៈ**ភាពតាមសភាវៈនៃអ្នកជំងឺ**...។* http://www.measboralaws.com/detail/1052។

**ឯកសារយោង**៖ **1**. Catherine Elliott, French Criminal Law, 2001, pp. 61-63; **2**. Catherine Elliott and Frances Quinn, Criminal Law, 2006, pp.10-12, 110-112; **3.** Jonathan Herring, Criminal law, Thrid Ed., 2015, pp. 24-44; **4**. Eugene McLaughlin and John Muncie, The Sage Dictionary of Criminology, 2006, p. 34 and **5.** Kevin Jon Heller and Markus D. Dbber, the Handbook of Comparative Criminal Law, 2011, pp. 223, 268, 298.